ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 23 / 08 / 2011
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

E62/3/10/4.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

កាលបរិច្ឆេទ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១១

**ជូនចំពោះ៖** សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

ភាគីទាំងអស់នៃ សំណុំរឿង ០០២

**ពី៖** ចៅក្រម Jean-Marc LAVERGNE ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** ចៅក្រមទាំងឡាយនៃអង្គជំនុំជម្រះសាលាដំបូង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** មតិជំទាស់របស់ចៅក្រម Jean-Marc Lavergne ពាក់ព័ន្ធនិងសេចក្តីសម្រេចដែលចេញដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងអនុស្សរណៈ E62/3/10/4[1]

១. ដើម្បីយល់អំពីប្រវត្តិនៃនីតិវិធីដែលឈានទៅដល់ការចេញសេចក្តីសម្រេចមួយដែលខ្ញុំពុំមានការយល់ស្រប យើងគួររំឭកថា៖

[1] សេចក្តីសម្រេចលើ "សារណាបន្ទាន់ស្នើសុំអង្គជំនុំជម្រះសាលាដំបូងឱ្យកែតម្រូវអនុស្សរណៈ E62/3/10" (ឯកសារ E62/3/10/1) ដាក់ដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ; និងសេចក្តីសម្រេចដែលត្រូវបានកែសម្រួល ឯកសារ E62/3/10/4/corr1។

- ក្នុងការឆ្លើយតបទៅនឹងសំណើសុំរបស់មេធាវីការពារក្តីជនជាប់ចោទបីរូប ក្នុងចំណោមជនជាប់ចោទទាំងឡាយ ដែលបានលើកឡើងពីបញ្ហាសុខភាពថាអាចធ្វើឲ្យប៉ះពាល់ដល់ការចូលរួមរបស់ពួកគេក្នុងសវនាការ អង្គជំនុំជម្រះសាលាដំបូងបានចាត់តាំងគ្រូពេទ្យជំនាញមួយរូបខាងជំងឺមនុស្សចាស់ឲ្យធ្វើការពិនិត្យ និងធ្វើការវាយតម្លៃស្ថានភាពជាក់ស្តែងរបស់ជនជាប់ចោទទាំងនោះ។ ការដែលអង្គជំនុំជម្រះធ្វើដូច្នេះ ដោយមូលហេតុថា ប្រសិនរកឃើញអំពីការលំបាកខ្លាំងដែលធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធភាពរបស់ជនជាប់ចោទក្នុងការអនុវត្តនូវសិទ្ធិរបស់ខ្លួននោះ វាអាចនាំឲ្យឈានទៅបញ្ឈប់ជាបណ្តោះអាសន្ន ឬ ជាស្ថាពរ នូវកិច្ចដំណើរការនីតិវិធីដែលពាក់ព័ន្ធទៅនឹងជនជាប់ចោទរូបនោះ។
- អ្នកជំនាញដែលត្រូវបានចាត់តាំង បានដាក់របាយការណ៍របស់ខ្លួនមុនពេលសវនាការបឋម។ របាយការណ៍នេះត្រូវបានចាត់ចំណាត់ថ្នាក់ជាប្រភេទ "ឯកសារសម្ងាត់បំផុត[2]" ហើយត្រូវបានផ្ញើជូនមេធាវីការពារក្តីជនជាប់ចោទពាក់ព័ន្ធ។ ក៏ប៉ុន្តែ នៅក្នុងអំឡុងសវនាការបឋម អង្គជំនុំ-ជម្រះសាលាដំបូងបានប្រកាសថារបាយការណ៍ទាំងនេះ ព្រមទាំងសេចក្តីអត្ថាធិប្បាយ ឬសេចក្តីជំទាស់នានាពាក់ព័ន្ធនឹងរបាយការណ៍នោះ នឹងត្រូវដាក់ទៅក្នុងសំណុំរឿង ក្រោមចំណាត់ថ្នាក់ "ឯកសារសម្ងាត់"[3] បន្ទាប់ពីផុតរយៈពេលដែលអង្គជំនុំជម្រះផ្តល់ឲ្យមេធាវីការពារក្តីដាក់សារណារបស់ខ្លួនជាលាយលក្ខណ៍អក្សរពាក់ព័ន្ធទៅនឹងការធ្វើកោសលវិច័យនេះ។

---

2 យោងតាមសេចក្តីណែនាំអនុវត្តស្តីពីការ"ចាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង"៖"ឯកសារប្រភេទ "សាធារណៈ" សំដៅដល់ឯកសារដែលសាធារណជនអាចចូលមើលបាន ហើយដែលការផ្សព្វផ្សាយព័ត៌មានទាំងនោះ មិនត្រូវបានរឹតត្បិត; ឯកសារប្រភេទ "សម្ងាត់" គឺរាល់ឯកសារទាំងឡាយណា ដែលមានតែចៅក្រម សហព្រះរាជអាជ្ញា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តី បុគ្គលិករបស់ អ.វ.ត.ក ដែលទទួលបាននីតិសម្បទា និងរាល់បុគ្គលផ្សេងទៀតដែលទទួលបាននីតិសម្បទាពី អ.វ.ត.ក ប៉ុណ្ណោះ ដែលអាចចូលមើលបាន; ឯកសារប្រភេទ "សម្ងាត់បំផុត" គឺសំដៅដល់រាល់ឯកសារទាំងឡាយណាដែលមានតែចៅក្រម និងបុគ្គលមួយចំនួនដែលជាបុគ្គលិករបស់ អ.វ.ត.ក ប៉ុណ្ណោះដែលអាចចូលមើលបាន ហើយការចូលមើលឯកសារសម្ងាត់បំផុតនេះ ត្រូវបានផ្តល់ដោយ អ.វ.ត.ក ដើម្បីអនុញ្ញាតឲ្យបុគ្គលិកទាំងនោះអាចបំពេញភារកិច្ចរបស់ខ្លួន"។

3 ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ២៥ ដល់ ទំព័រ២៨។

- ក្នុងការឆ្លើយតបទៅនឹងសំណើសុំដែលបានដាក់ដោយជនជាប់ចោទពីររូប ក្នុងចំណោមជនជាប់ចោទទាំងអស់ ដែលបានជំទាស់ទៅនឹងចំណាត់ថ្នាក់ឯកសារ "សម្ងាត់" ចំពោះឯកសារទាំងនេះ[4] អង្គជំនុំជម្រះសាលាដំបូងបានសម្រេច រក្សាចំណាត់ថ្នាក់ឯកសារនេះនៅជាសម្ងាត់បំផុតដដែល ដោយយោងទៅលើភាពចាំបាច់ក្នុងការធានាឲ្យមានភាពរាប់រហ័សនៃនីតិវិធី និងជាពិសេស ដោយយោងទៅលើរយៈពេលដែលផ្តល់ដល់ភាគីសម្រាប់ធ្វើការឆ្លើយតបទៅនឹងសារណារបស់មេធាវីការពារក្តី។ ការសម្រេចដូច្នេះដោយអង្គជំនុំជម្រះផ្អែកតែទៅលើមូលដ្ឋាននៃសេចក្តីជំទាស់របស់ជនជាប់ចោទប៉ុណ្ណោះ[5]។ វាច្បាស់ណាស់ថា សេចក្តីសម្រេចនេះអាចត្រូវបានចាត់ទុកថាមានលក្ខណៈបណ្តោះអាសន្ន។ ចំណុចនេះមានលក្ខណៈត្រឹមត្រូវ ដោយហេតុថា ជនជាប់ចោទទី៣ បានស្នើសុំនាពេលក្រោយមកឲ្យរបាយការណ៍កោសលវិច័យវេជ្ជសាស្ត្រ ដែលពាក់ព័ន្ធនឹងខ្លួនត្រូវបានចាត់ថ្នាក់ជាប្រភេទឯកសារ "សាធារណៈ" វិញ។ មកទល់នឹងពេលនេះពុំមានចម្លើយតបណាមួយទៅនឹងសំណើសុំរបស់ជនជាប់ចោទរូបនេះនៅឡើយ។ ក៏ប៉ុន្តែ របាយការណ៍ដែលពាក់ព័ន្ធនឹងជនជាប់ចោទរូបនេះត្រូវបានចាត់ថ្នាក់ជាប្រភេទឯកសារ"សម្ងាត់" ដូច្នេះ មេធាវីរបស់ភាគីទាំងឡាយនៃរឿងក្តីរួមបញ្ចូលទាំងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ[6] អាចចូលទៅមើលឯកសារនេះបាន។

២. ជាបឋម ខ្ញុំសូមធ្វើការជំទាស់ទៅលើចំណុចដែលពាក់ព័ន្ធទៅនឹងគោលការណ៍នៃការធ្វើចំណាត់ថ្នាក់ឯកសារ ឬកាន់តែច្បាស់ជាងនេះ គឺទៅលើការដាក់កម្រិតដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលមើលរបាយការណ៍កោសលវិច័យវេជ្ជសាស្ត្រនោះ។ បន្ទាប់មកទៀត ខ្ញុំសូមធ្វើការជំទាស់ផងដែរទៅលើការវិភាគអំពីការទទួលខុសត្រូវរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើការរៀបចំប្រព័ន្ធនៃការតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលកើតចេញពីអនុស្សរណៈលេខ E62/3/10/4។

[4] សូមមើលឯកសារ E62/3/7 (ពាក់ព័ន្ធនឹងជនជាប់ចោទ អៀង ធីរិទ្ធ) និងឯកសារ E62/3/8 (ពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជា)។

[5] ដោយឡែក សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានអនុញ្ញាតឲ្យធ្វើសេចក្តីសង្កេតជាក់លាក់ណាមួយឡើយ ព្រោះសហមេធាវីនាំមុខពុំមានរបាយការណ៍កោសល្យវិច័យវេជ្ជសាស្ត្រនោះទេ ដែលផ្ទុយពីសហព្រះរាជអាជ្ញា។

[6] ឯកសារ E62/3/5។

**១) ការដាក់កម្រិតចំពោះសិទ្ធិទទួលបានរបាយការណ៍កោសលវិច័យវេជ្ជសាស្ត្រ ដល់ដើមបណ្ដឹងរដ្ឋប្បវេណី មិនមានហេតុផលសមស្រប ដោយហេតុថារបាយការណ៍នេះជាធាតុផ្សំនៃឥស្សតាងដែលត្រូវដាក់នៅក្នុងកិច្ចពិភាក្សាដេញដោលរបស់តុលាការ ដែលកិច្ចពិភាក្សានេះត្រូវធ្វើឡើងចំពោះមុខភាគីទាំងអស់ដោយគ្មានការលើកលែង ហើយត្រូវប្រព្រឹត្តទៅប្រកបដោយតម្លាភាព តាមដែលអាចធ្វើទៅបាន។**

៣. ជាបឋម យើងគួររំឭកផងដែរថា នៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរលើសំណុំរឿង ០០២ ឬនៅក្នុងក្របខណ្ឌនៃសំណុំរឿង ០០១ របាយការណ៍កោសលវិច័យវេជ្ជសាស្ត្រពាក់ព័ន្ធទៅនឹងសមត្ថភាពរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះ ឬពាក់ព័ន្ធនឹងការពិនិត្យទៅលើអត្តចារិតរបស់ជនជាប់ចោទ ជាពិសេសទៅលើស្ថានភាពវិកលចារិត ត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង។ ហើយជាទូទៅ ឯកសារទាំងនេះតែងតែត្រូវបានចាត់ថ្នាក់ជាប្រភេទឯកសារ "សម្ងាត់" [7]។ របាយការណ៍កោសលវិច័យលើស្ថានភាពវិកលចារិត និងចិត្តសាស្ត្ររបស់ជនជាប់ចោទកាំង ហ្កេកអ៊ាវ ត្រូវបានលើកយកមកជជែកដេញដោលក្នុងសវនាការជាសាធារណៈ ដោយអង្គជំនុំជម្រះមិនព្រួយបារម្ភថា ព័ត៌មានវេជ្ជសាស្ត្រដែលមានលក្ខណៈផ្ទាល់ខ្លួន អាចត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយឡើយ។

៤. ការអនុវត្តដែលអនុញ្ញាតឱ្យមេធាវីទាំងអស់ រួមទាំងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ចូលមើលរបាយការណ៍កោសលវិច័យវេជ្ជសាស្ត្រដែលដាក់បញ្ចូលក្នុងសំណុំរឿង ត្រូវបានជំទាស់ដោយអង្គជំនុំជម្រះ ដោយអង្គជំនុំជម្រះបានលើកហេតុផលទីមួយពាក់ព័ន្ធនឹងតម្រូវការក្នុងការធ្វើឱ្យមានតុល្យភាព រវាងសិទ្ធិរបស់ជនជាប់ចោទដែលត្រូវទទួលបានការគោរពជីវិតឯកជនរបស់ខ្លួនពាក់ព័ន្ធនឹងព័ត៌មានវេជ្ជសាស្ត្រ និងសិទ្ធិរបស់សាធារណជនក្នុងការដឹងអំពីមូលដ្ឋាននៃសំណើ ដែលដាក់ដោយជនជាប់ចោទមួយរូប ដើម្បីជំទាស់ទៅនឹងសមត្ថភាពរបស់ខ្លួនក្នុងការទទួលការជំនុំជម្រះ។ ចំពោះខ្ញុំ ការពន្យល់ថ្មីនេះហាក់ដូចជាពុំមានមូលដ្ឋានគតិយុត្ត

---

[7] របាយការណ៍កោសល្យវិច័យផ្នែកចិត្តសាស្ត្រ រៀបរៀងឡើងដោយសាស្ត្រាចារ្យ Philip Brinded និងសាស្ត្រាចារ្យ កា ស៊ុនបូណាត ឯកសារ B36/5, B35/7, B38/4 និង B37/9/8; របាយការណ៍កោសល្យវិច័យចិត្តសាស្ត្រ រៀបរៀងឡើងដោយសាស្ត្រាចារ្យ Françoise Sironi-Guilbaud និងសាស្ត្រាចារ្យ កា ស៊ុនបូណាត, សំណុំរឿងលេខ ០០១/១៨ កក្កដា ២០០៧/អវតក/អជសដ ឯកសារ E3/509។

គ្រប់គ្រាន់ក្នុងការដកនូវមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចេញអំពីបញ្ជីឈ្មោះបុគ្គលដែល មានសិទ្ធិចូលមើលរបាយការណ៍កោសលវិច័យវេជ្ជសាស្ត្រនោះឡើយ។

៥. ព័ត៌មានវេជ្ជសាស្ត្រដែលមាននៅក្នុងរបាយការណ៍កោសលវិច័យ ត្រូវបានប្រមូលដោយវេជ្ជបណ្ឌិតជំនាញដែលត្រូវបានចាត់តាំងឡើងដោយតុលាការ ពុំមែនដោយភាគីឡើយ ដើម្បីឆ្លើយតបទៅនឹងការបំពេញភារកិច្ចមួយច្បាស់លាស់។ ភារកិច្ចនេះគឺការពិនិត្យលើភាពសមស្របនៃសំណើសុំរបស់ជនជាប់ចោទដែលថា ខ្លួនពុំមានសមត្ថភាព អាចទទួលការជំនុំជម្រះបាននោះ។ រាល់ព័ត៌មានផ្សេងទៀតដែលពុំមានលក្ខណៈសមហេតុផលដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ មិនត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ឡើយ ព្រោះអាចត្រូវបានចាត់ទុកផងដែរថាជាការរំលោភលើការសម្ងាត់ផ្នែកវេជ្ជសាស្ត្រ។ ម្យ៉ាងវិញទៀត អ្នកជំនាញក៏ត្រូវជូនដំណឹងដល់ជនជាប់-ចោទផងដែរអំពីប្រភេទជាក់លាក់នៃភារកិច្ចដែលខ្លួនត្រូវបំពេញដើម្បីជៀសវៀងកុំឱ្យមានការយល់ច្រឡំរវាងការងារធ្វើកោសលវិច័យជាមួយនឹងការងារជាគ្រូពេទ្យព្យាបាល។ ដូច្នេះ អ្នកជំនាញរូបនោះ ក៏ត្រូវរក្សាទំនាក់ទំនងរវាងអ្នកជំនាញ និងជនជាប់ចោទ ក្នុងក្របខណ្ឌនៃភារកិច្ចតុលាការដែលខុសគ្នាទៅនឹងភារកិច្ចដែលធ្លាប់បំពេញដោយវេជ្ជបណ្ឌិតចំពោះអ្នកជំងឺរបស់ខ្លួន។

៦. ដើម្បីបំពេញភារកិច្ចរបស់ខ្លួននោះ ជាការចាំបាច់អ្នកជំនាញត្រូវប្រមូលនូវព័ត៌មានវេជ្ជសាស្ត្រសមហេតុ-ផលដើម្បីធ្វើការវាយតម្លៃវិសាលភាពនៃការអះអាងរបស់ជនជាប់ចោទ ពាក់ព័ន្ធនឹងបញ្ហាសុខភាពរបស់ខ្លួន។ ភស្តុតាងដែលប្រមូលបាន និងការវិភាគដែលធ្វើឡើងដោយអ្នកជំនាញ ត្រូវដាក់ឱ្យជជែកដេញដោលនៅចំពោះមុខភាគីទាំងអស់ ដោយគ្មានការបែងចែក។ ដូច្នេះ វាច្បាស់ណាស់ថា នៅពេលបំពេញភារកិច្ចដែលប្រគល់ជូនអ្នកជំនាញ ក្នុងក្របខណ្ឌនៃភារកិច្ចតុលាការដែលអ្នកជំនាញរូបនោះត្រូវបានចាត់តាំងឱ្យបំពេញនោះ ការសម្ងាត់ផ្នែកវេជ្ជសាស្ត្រដែលអាចពាក់ព័ន្ធនឹងព័ត៌មានទាំងនោះ ត្រូវប្រគល់ជូនទៅតុលាការ ឬភាគីពាក់ព័ន្ធ បើមិនដូច្នេះទេ វានឹងធ្វើឱ្យសញ្ញាណនៃសវនាការដេញដោលចំពោះមុខគ្មានន័យខ្លឹមសារឡើយ។

៧. ដោយផ្អែកលើលក្ខណៈពិសេសនេះហើយ ទើបប្រព័ន្ធច្បាប់រ៉ូម៉ាំង-អាល្លឺម៉ង់ (ប្រព័ន្ធច្បាប់ស៊ីវិល) ដូចជាប្រព័ន្ធច្បាប់បារាំង ឬប្រព័ន្ធច្បាប់កម្ពុជា ពុំមានចែងអំពីប្រព័ន្ធនៃការចាត់ថ្នាក់របាយការណ៍កោសល-វិច័យវេជ្ជសាស្ត្រដែលមាននៅក្នុងសំណុំរឿង ដែលហាមឃាត់មិនឱ្យមេធាវីរបស់ភាគីទទួលបានព័ត៌មានអំពីរបាយការណ៍នោះឡើយ។ ម្យ៉ាងវិញទៀត គោលការណ៍នៃសិទ្ធិរបស់មេធាវីក្នុងការចូលមើលឯកសារទាំងអស់នៃសំណុំរឿងគឺមានចែងក្នុងវិធាន ២២(៣) នៃវិធានផ្ទៃក្នុង។ ក៏ប៉ុន្តែ សិទ្ធិនេះមិនមែនជាឧបសគ្គក្នុងការចាត់

ថ្នាក់របាយការណ៍ទាំងនេះ ជាឯកសារប្រភេទ "សម្ងាត់" ឡើយ ដរាបណា មេធាវីអាចចូលមើលឯកសារទាំងនោះបានដើម្បីប្រសិទ្ធិភាពនៃការការពារក្តី។ ម្យ៉ាងវិញទៀត ការដឹងនូវរាល់ព័ត៌មានលម្អិតទាំងនេះ មិនមែនជាកាតព្វកិច្ចរបស់កូនក្តីខ្លួននោះទេ។

៨. ក្នុងករណីនេះ ពុំមានជនជាប់ចោទណាម្នាក់អះអាងថា របាយការណ៍ទាំងនេះផ្ទុកនូវព័ត៌មានទាំងឡាយដែលពុំមានទំនាក់ទំនងជាមួយនឹងភារកិច្ចរបស់អ្នកជំនាញនោះដែរ។ ក្នុងការលើកឡើងនូវទឡ្ហីករណ៍ដែលទាញចេញអំពីសិទ្ធិទទួលបានការគោរពជីវិតឯកជន ដើម្បីជំទាស់ទៅនឹងការផ្សព្វផ្សាយព័ត៌មានវេជ្ជសាស្ត្រ ដែលជនជាប់ចោទខ្លួនឯងផ្ទាល់បានស្នើសុំឱ្យមានការប្រមូលនូវព័ត៌មានទាំងនោះមានលក្ខណៈមិនសមហេតុផល នៅខណៈដែលការផ្សព្វផ្សាយព័ត៌មានទាំងនោះមានលក្ខណៈចាំបាច់សម្រាប់ធានាឱ្យមានអត្ថិភាពនៃសវនាការដេញដោលចំពោះមុខពិតប្រាកដមួយស្តីអំពីអត្ថិភាពនៃការជំនុំជម្រះក្តីនោះ។

៩. ចំណុចនេះមានលក្ខណៈត្រឹមត្រូវទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ក្នុងឋានៈជាជនរងគ្រោះផ្ទាល់នៃបទល្មើសដែលជនជាប់ចោទត្រូវទទួលខុសត្រូវ។ ទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះអនុវត្តសិទ្ធិរបស់ខ្លួនជាលក្ខណៈបុគ្គលក្តី ឬជាសមូហភាពក្តី ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ចង់ឱ្យសវនាការអាចត្រូវបានប្រព្រឹត្តទៅដោយមានប្រសិទ្ធភាព។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិលើកឡើងនូវទឡ្ហីករណ៍នានា ដើម្បីជំទាស់ទៅនឹងការបញ្ចប់កិច្ចដំណើរការនីតិវិធី ក៏ដូចជាដើម្បីដេញដោលលើភស្តុតាងដែលមេធាវីការពារក្តីមានបំណងលើកឡើងនៅក្នុងសវនាការដែរ។

១០. នៅក្នុងបរិបទពិសេសនៃរឿងក្តីដែលស្ថិតក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះ វាពិតប្រាកដហើយថាសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីរាប់ពាន់នាក់ ដែលបានដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសិទ្ធិទាំងនេះមានលក្ខណៈសំខាន់ណាស់ ដោយហេតុថាការចោទប្រកាន់លើជនជាប់ចោទមានលក្ខណៈធ្ងន់ធ្ងរ ហើយដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះបានរង់ចាំយុត្តិធម៌អស់រយៈពេលយ៉ាងយូរ ដែលធ្វើឱ្យរឿងក្តីនេះមានលក្ខណៈជាប្រវត្តិសាស្ត្រ។ ការទន្ទឹងរង់ចាំនេះកើតមានឡើងផងដែរក្នុងស្រទាប់សាធារណជនដែលតាមដានសកម្មភាពរបស់ អ.វ.ត.ក។ អ្នកទាំងនោះមានបំណងចង់ឱ្យមានការជំនុំជម្រះក្តី ហើយប្រសិនជាមានកិច្ចពិភាក្សាពាក់ព័ន្ធនឹងការបញ្ឈប់ការចោទប្រកាន់ណាមួយនោះ ប្រសិនបើមានគឺត្រូវធ្វើឡើងជាសាធារណៈនិងប្រកបដោយតម្លាភាព។ ទាំងនេះគឺជាធាតុផ្សំមួយដែលអង្គជំនុំជម្រះត្រូវធ្វើការវាយតម្លៃថា តើអង្គជំនុំជម្រះ

ត្រូវធ្វើការសម្រេចលើសំណើសុំឱ្យមានសវនាការជាសម្ងាត់ ឬយ៉ាងណា ពាក់ព័ន្ធទៅនឹងបញ្ហានេះនោះ ពីព្រោះវាជាការកំណត់ថាតើយើងត្រូវតម្កល់ផលប្រយោជន៍យុត្តិធម៌នៅទីណា។

**២) វិធានការដកសេចក្តីទុកចិត្តសំដៅដកជាគោលការណ៍នូវមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីពីបញ្ជីឈ្មោះបុគ្គលដែលអនុញ្ញាតឲ្យចូលមើលរបាយការណ៍កោសលវិច័យវេជ្ជសាស្ត្រ។ វិធានការនេះពុំអាចទាញអំណះអំណាងចេញពីការផ្លាស់ប្តូរឋានៈរបស់មេធាវីទាំងនោះ ឬដោយសារការ "ការរៀបចំ" ថ្មី ដោយ អ.វ.ត.ក ដើម្បីធានាការការពារផលប្រយោជន៍របស់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណី នៅដំណាក់កាលជំនុំជម្រះនោះទេ។ វិធានការនេះធ្វើឲ្យប៉ះពាល់ដល់ការតំណាងផលប្រយោជន៍របស់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណី។**

១១. ការហាមឃាត់ជាគោលការណ៍ មិនឱ្យចូលមើលរបាយការណ៍កោសលវិច័យវេជ្ជសាស្ត្ររបស់លោកសាស្ត្រាចារ្យ Campbell ដែលអនុវត្តទៅលើមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនអាចត្រូវបានពន្យល់ឱ្យសមហេតុផល ដោយផ្អែកតែទៅលើប្រការដែលថា នីតិវិធីបានឈានដល់ដំណាក់កាលនៃការជំនុំជម្រះបានទេ។ មេធាវីទាំងនេះ គឺជាមេធាវីដែលបានចូលរួមតាំងពីដំណាក់កាលស៊ើបសួរ ដែលនៅពេលនោះ សិទ្ធិរបស់ពួកគេក្នុងការចូលមើលព័ត៌មានប្រភេទនេះ ពុំត្រូវបានគេលើកយកទៅពិភាក្សាឡើយ។ ការដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលនូវសំណុំរឿង ពុំអាចផ្លាស់ប្តូរវិសាលភាពនៃកាតព្វកិច្ចតាមក្រមសីលធម៌វិជ្ជាជីវៈរបស់មេធាវីទាំងនោះក្នុងការរក្សាការសម្ងាត់របស់ឯកសារដែលពួកគេចូលមើល ហើយក៏មិនកែប្រែការទទួលខុសត្រូវរបស់ពួកគេចំពោះកូនក្តីបានដែរ បើទោះជាសិទ្ធិរបស់កូនក្តីអនុវត្តនៅក្នុងក្របខណ្ឌនៃបណ្តុំដើមបណ្តឹងរដ្ឋប្បវេណី និងក្រោម ការសម្របសម្រួល និងការទទួលខុសត្រូវចុងក្រោយរបស់សហមេធាវីនាំមុខក៏ដោយ។ ម្យ៉ាងវិញទៀត ពុំមានភស្តុតាងណាមួយដែលបង្ហាញថា ព័ត៌មានវេជ្ជសាស្ត្រផ្ទាល់ខ្លួនរបស់ជនជាប់ចោទអាចត្រូវបានផ្សព្វផ្សាយ ដោយមិនសមស្របឡើយ ហើយរិតតែពុំមានភស្តុតាងណាមួយដែលបញ្ជាក់ថា ការផ្សព្វផ្សាយនោះមានប្រភព ចេញមកពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។

១២. ខ្ញុំយល់ឃើញថា វាហាក់ដូចជាមិនមានហេតុផលសមស្របឡើយ ដែលដកសេចក្តីទុកចិត្ត និងរើសអើងចំពោះមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែពួកគេមានគ្នាច្រើន។ ជាក់ស្តែង ជាដំបូង វាគឺ

ជាបញ្ហាគោលការណ៍ ដែលមិនអាស្រ័យទៅនឹងចំនួនតិច ឬច្រើននៃមេធាវីពាក់ព័ន្ធឡើយ។ ចំនួនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីច្រើន គ្រាន់តែចង់បង្ហាញអំពីសារៈសំខាន់នៃការការពារផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ។ លើសពីនេះទៅទៀត ផ្អែកទៅលើគោលការណ៍ ហើយដោយសន្មត់ថាប្រភេទនៃមន្ត្រីមួយចំនួនអាចមិនត្រូវបានអនុញ្ញាតឲ្យចូលមើលសំណុំរឿងក៏ដោយ ខ្ញុំមិនយល់ថាហេតុអ្វីបានជាត្រូវធ្វើការបែងចែករវាងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តីជនជាប់ចោទនោះទេ ពីព្រោះមេធាវីការពារក្តីអាចចូលមើលព័ត៌មានវេជ្ជសាស្ត្រពាក់ព័ន្ធទៅនឹងជនជាប់ចោទដែលជាកូនក្តីរបស់ខ្លួន។ ខ្ញុំក៏ពុំបានមើលឃើញផងដែរអំពីភាពសមស្របនៃការហាមឃាត់ជាគោលការណ៍ ដែលមានគោលដៅដកហូតពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនូវលទ្ធភាពពិគ្រោះយោបល់ជាមួយមេធាវីនាំមុខ ដើម្បីបញ្ចេញមតិរបស់ខ្លួនជាពិសេសទៅលើការចោទជាបញ្ហាទៅលើរោគវិនិច្ឆ័យពីមុន និងទៅលើឧបទ្ទវហេតុនៃការវិវត្តផ្នែកសុខភាពរបស់ជនជាប់ចោទ ពាក់ព័ន្ធនឹងការចូលរួមក្នុងការជំនុំជម្រះក្តី។

១៣. ជាទីបញ្ចប់ ខ្ញុំយល់ឃើញថា ការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់សហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានលក្ខណៈខុសឆ្គង។ ទម្រង់ដែលចង់បានដោយសម័យប្រជុំពេញអង្គ ហើយដែលទាញចេញពីវិធាន ១២ស្ទួនពីរ និងវិធាន ២៣ គឺជាទម្រង់នៃការទទួលខុសត្រូវចែករំលែករវាងសហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងកិច្ចការងារតំណាងផលប្រយោជន៍របស់សមូហភាពនៃដើមបណ្តឹងរដ្ឋប្បវេណី។

១៤. ជាក់ស្តែង ទោះបីជាវិធានទាំងនេះបានផ្តល់ដល់សហមេធាវីនាំមុខនូវការទទួលខុសត្រូវចុងក្រោយនៅចំពោះមុខអង្គជំនុំជម្រះទាក់ទងនឹងបញ្ហាទូទៅនៃការតំណាង យុទ្ធសាស្ត្រ និងការឡើងថ្លែងផ្ទាល់មាត់អំពីផលប្រយោជន៍របស់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានការទទួលខុសត្រូវជាបឋមដែលកើតចេញពី "ករណីយកិច្ចដំបូង" របស់ខ្លួន ពោលគឺ ការ"ស្វែងរកទស្សនៈផ្សេងៗពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងព្យាយាមសម្របសម្រួលឲ្យអស់ពីលទ្ធភាពឈានទៅដល់ការឯកភាពគ្នាជាឯកច្ឆន្ទ ក្នុងការធ្វើជាតំណាងដើមបណ្តឹងរដ្ឋប្បវេណី"។ ដូច្នេះ ការទទួលខុសត្រូវ "ចុងក្រោយ" ធ្លាក់ទៅលើសហមេធាវីនាំមុខតែមួយគត់ នៅពេលដែលខ្លួនពុំអាចឈានទៅដល់ការឯកភាពគ្នាជាឯកច្ឆន្ទ។ ដំណាក់កាលបឋមនៃការពិគ្រោះយោបល់ ពុំមែនធ្វើឡើងតាមជ្រើសឡើយ ហើយរឹតតែពុំអាចទៅទៀត ក្នុងករណីពាក់ព័ន្ធនឹងការពិភាក្សាដេញដោលទៅលើអត្ថិភាពនៃការជំនុំជម្រះក្តីនោះ។

១៥. នៅក្នុងស្ថានភាពនេះ ការហាមឃាត់ជាគោលការណ៍ដែលអនុវត្តទៅលើមេធាវីតំណាងដើមបណ្តឹង-រដ្ឋប្បវេណីក្នុងការចូលមើលរបាយការណ៍វេជ្ជសាស្ត្រខាងលើ ធ្វើឱ្យសហមេធាវីនាំមុខបាត់បង់លទ្ធភាពក្នុងការពិគ្រោះយោបល់យ៉ាងមានប្រសិទ្ធភាពជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្តីអំពីយុទ្ធសាស្ត្រដែលត្រូវអនុវត្ត ពាក់ព័ន្ធនឹងផលវិបាកនានាដែលអាចកើតចេញពីរបាយការណ៍របស់សាស្ត្រាចារ្យ Campbell។ នេះគឺជាស្ថានភាពមួយដែលបង្កនូវព្យសនកម្មដោយជៀសមិនផុតទៅលើការតំណាងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលអង្គជំនុំជម្រះត្រូវតែធានាឱ្យបាន។

១៦. ម្យ៉ាងវិញទៀត មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានកាតព្វកិច្ចប្រឹងប្រែងក្នុងការផ្តល់ការគាំទ្រដល់សហមេធាវីនាំមុខ និងនៅក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀងទ្វេភាគីរវាងសហមេធាវីនាំមុខ និង "មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធ"។ បណ្តុំដើមបណ្តឹងរដ្ឋប្បវេណីគឺជាសញ្ញាណអរូបី ក៏ប៉ុន្តែ ការជំនុំជម្រះក្តីបានបង្ហាញយ៉ាងច្បាស់ អំពីស្ថានភាពដែលដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗមានជាប់ពាក់ព័ន្ធនិងនីតិវិធីជាពិសេស នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ត្រូវមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ។ នៅក្នុងស្ថានភាពដែលដើមបណ្តឹងរដ្ឋប្បវេណីធ្វើអន្តរាគមន៍ជាលក្ខណៈបុគ្គលផ្ទាល់ វាជាក់ច្បាស់ណាស់ថា "ជំនួយ" ដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីត្រូវផ្តល់ជូនដើមបណ្តឹងរដ្ឋប្បវេណីមានលក្ខណៈសំខាន់បំផុត។ ស្ថានភាពនេះមានលក្ខណៈដូចគ្នា ក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណីទាំងមូល "ជាអ្នកពាក់ព័ន្ធ"។ បញ្ហាដែលពាក់ព័ន្ធទៅនិងសមត្ថភាពរបស់ជនជាប់ចោទម្នាក់ដែលអាចទទួលបាននូវការជំនុំជម្រះ គឺជាបញ្ហាមួយក្នុងចំណោមបញ្ហាទាំងនេះ។ ជាក់ស្តែង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះមិនត្រឹមតែបានធ្វើឱ្យសហមេធាវីនាំមុខបាត់បង់លទ្ធភាពក្នុងការប្រឹក្សាយោបល់យ៉ាងមានប្រសិទ្ធភាពជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះទេ ប៉ុន្តែសេចក្តីសម្រេចនោះថែមទាំងបានធ្វើឱ្យសហមេធាវីនាំមុខធ្លាក់ទៅក្នុងស្ថានភាព "លំបាក" ពោលគឺពុំអាចមានលទ្ធភាពក្នុងការស្វែងរកជំនួយពីសំណាក់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើមូលដ្ឋាននៃកិច្ចព្រម-ព្រៀងទ្វេភាគីជាមួយមេធាវីដើបណ្តឹងរដ្ឋប្បវេណីណាម្នាក់ ក្នុងចំណោមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំង-អស់ ឬជាមួយមេធាវីបរទេសម្នាក់ និងមេធាវីកម្ពុជាម្នាក់។ ចំណុចនេះ ក៏អាចបង្កើតឱ្យមានជាព្យសនកម្មចំពោះការតំណាងឱ្យផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដែរ។